សការព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០៤ លេខ ៦៦៤ ចេញផ្សាយថ្ងៃ អង្គារ ទី ២៥ ខែ ឧសភា ឆ្នាំ ២០១០

## តង់ គាំ : ខ្ញុំមិនដឹងថាអង្គការ Global Witness ឬក៏ហោណាំហុងទេដែលជាអ្នកឆ្កួតជ្រូកនោះ


លោក គង់ គាំ ប្រធានស្តីទីគណបក្សសមរង្ស៊ី


លោក ហោ ណាំបូរ៉ា


ឧកញ៉ា លី យ៉ុងផាត់


ឧកញ៉ាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា ម៉ុង ឬទ្ធី


ស្ថានភាពបូមខ្សាច់ក្នុងសមុទ្រខ្មែរយកទៅលក់នៅក្រៅប្រទេសរបស់ឧកញ៉ាមួយចំនួន

ដោយ : សូរ្យាទិត្យ

សង្គ្រាមពាក្យសម្តី រវាងអង្គការ Global Witness ជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជា បាននិងកំពុងចាប់ផ្តើម យ៉ាងក្តៅគគុកហើយ ។ ការឆាបឆេះសង្គ្រាមពាក្យសម្តីសាជាថ្មីឡើងវិញនេះ គឺបន្ទាប់ពីមន្ត្រីផ្លូវការ រាជរដ្ឋាភិបាលបដិសេធ មិនហ៊ានចេញមុខចោទសួរ ជាសាធារណៈជាមួយអង្គការ Global Witness

តទៅទំព័រទី៤ ម

## ម៉ៅ មុនីវណ្ណ ស្នើក្រសួងការងារមានវិធានការលើក្រុមហ៊ុន Equine Resources(Cambodia)Co.,Ltd


លោក ម៉ៅ មុនីវណ្ណ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលកំពង់ចាម


រដ្ឋមន្ត្រី វង សូត

ដោយ : វាសនា

រយៈពេលចុងក្រោយនេះប្រជាពលរដ្ឋ ដែលស្វែងរកទីផ្សារលក់កម្លាំងពលកម្មនៅក្រៅប្រទេសដើម្បីក្រពះនោះ បានជួបនូវបញ្ហាជាច្រើន ដោយសារតែមានក្រុមហ៊ុនខ្លះបោកប្រាស់មិនគោរពតាម លក្ខខណ្ឌ នៃការ

តទៅទំព័រទី៣ ឡ

## មន្ត្រីគណបក្សសមរង្ស៊ីរិះគន់រដ្ឋាភិបាលហ៊ុនសែនថាគ្មានជំហរច្បាស់លាស់រឿងព្រំដែន


លោក ហ៊ុន សែន និងមន្ត្រីយោធាជាន់ខ្ពស់របស់ប្រទេសកម្ពុជា


ទាហានសៀមនៅតែឈរជើងនៅក្នុងវត្តកែវសិក្ខាគីរីស្វារៈដដែល

ដោយ : ជ័យ តារា

នៅសល់ មិនដល់៣ខែទៀតទេ ទាហានសៀម ឈ្លានពានចូលមកក្នុងដីខ្មែរមានចំនួន២ឆ្នាំហើយ គឺគិតតាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨មកនោះ ។ នៅតំបន់ខ្លះ នៃទឹកដីកម្ពុជានៅតាមព្រំដែន ជាពិសេស វត្តកែវសិក្ខាគីរីស្វារៈ នៅតែមាន កងទ័ពសៀមប្រចាំការជាមួយនឹងទាហានខ្មែរដដែលហើយការឱ្យ

តទៅទំព័រទី៤ ន

## ល្បិចកលទុច្ចរិតក្នុងរឿងរំលោភសេចក្តីទុកចិត្តរបស់អ៊ុំងវិទ្ធាគេចមិនផុតពីកណ្តាប់ដៃតុលាការ


លោក ជា ចំរើន


ស្ត្រីជាប់សង្ស័យឈ្មោះ អ៊ឹង វិទ្ធា ដែលបច្ចុប្បន្នកំពុងឃុំខ្លួនក្នុងពន្ធនាគារ

ដោយ : គ.សំណាង

ឧបាយកលដ៏ពិសពុលរបស់ស្ត្រី *អ៊ុំងវិទ្ធា* ដែលត្រូវបានលោក *ជា ចំរើន* ប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញពីបទ "*រំលោភសេចក្តីទុកចិត្ត* " នោះ ពិតជាគេចមិនផុតពីកណ្តាប់ដៃតុលាការមែន ។ ព្រោះកាលពីព្រឹក

តទៅទំព័រទី៣ ញ

## ក្រុមគ្រួសារនាង អ៊ិន សុខលីដា និងយ៉ា សុខនីម ស្នើសុំតុលាការកំពូលពន្លឿននីតិវិធីរឿងក្តីនេះ


ជនរងគ្រោះដោយទឹកអាស៊ីត យ៉ា សុខនីម និងក្រុមគ្រួសារ


លោកស្រី ជា រដ្ឋា មេក្លោងឧក្រិដ្ឋជនដែលកំពុងរស់នៅក្នុងលំហរសេរីភាព

ដោយ : វិសាល

ក្រុមគ្រួសារអ្នកនាង *អ៊ិន សុខលីដា* និងអ្នកស្រី *យ៉ា សុខនីម* បានស្នើសុំយ៉ាងទទូចឱ្យតុលាការធ្វើយ៉ាងណាពន្លឿននីតិវិធីនៃរឿងក្តីដ៏ឧក្រិដ្ឋនេះ ដោយឆាប់រហ័សបំផុត ទើបជាការប្រសើរ ។ ព្រោះរហូតមកដល់ពេលនេះទៅហើយមេក្លោង និងបក្ខពួកជាឧក្រិដ្ឋជនកំពុងរស់នៅក្នុងលំហសេរីភាពនៅឡើយ

តទៅទំព័រទី២ ៥

## ក្រុមហ៊ុនទូរស័ព្ទយួនមិត្តហ្វូនគម្រាមប្រើលុយឱ្យចាប់បុគ្គលិកខ្មែរដាក់គុកក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍



ស្លាកសញ្ញាសម្គាល់របស់ក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូន

ដោយ : យុទ្ធ ពន្យ

ដំបូងគេគ្រាន់តែបានដឹងថាក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូនជាចំណែកនៃការកាន់កាប់របស់ក្រសួងការពារជាតិ នៃប្រទេសយួនជាមួយក្រសួងការពារជាតិកម្ពុជាដែលមានភាគហ៊ុនកម្រិតណានោះ ហើយឥឡូវរឿងថ្មីៗចេះ

តទៅទំព័រទី២ ស

### ដំណឹងលក់ដី

យើងខ្ញុំមានដីមួយកន្លែងទំហំ ៣០ម x ៣០ម នៅទល់មុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ ទីតាំងដីនោះនៅចម្ងាយប្រមាណ៥០០ម៉ែត្រពីភ្លើងស្តុបព្រលានយន្តហោះ ជាប់កាច់ជ្រុងផ្លូវបេតុង ស្ថិតនៅក្នុងភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោរាជធានីភ្នំពេញ ដែលមានទឹក និងភ្លើងរដ្ឋ ។

ទីតាំងនៃដីនោះស្ថិតនៅទីប្រជុំជន មានផ្សារ រោងចក្រ អាចធ្វើផ្ទះសំណាក់ ខុនដូ ហើយលក់ក្នុងតម្លៃ ៦៥ម៉ឺនដុល្លារអាមេរិក ដែលជាតម្លៃអាចនិយាយចរចាគ្នាបាន ។ បើអតិថិជនចាប់អារម្មណ៍ សូមទំនាក់ទំនងទូរស័ព្ទលេខ **០១៦ ២៩ ៥៦ ៥៦** ។

**សូមអរគុណ**

## កុងត្រូលជជុះប្រឆាំងនឹងបទបញ្ជាហ៊ុនសែន

ដោយ : សីហា

ក្រុមអ្នក បើកបរ រថយន្តឈ្នួល និងរថយន្តដឹកទំនិញ រ៉ឺម៉កគោយន្តនៅតាមខេត្ត ក្រុងមួយចំនួន ក្នុងប្រទេសកម្ពុជា បាននាំគ្នារអ៊ូរទាំថា កុងត្រូលជជុះ បាននិងកំពុងតែកើតមានច្រើនកន្លែង នៅតាមផ្លូវសាធារណៈដែលដាក់ជ្រកក្រោមស្លាកការអនុវត្តន៍ច្បាប់ ចរាចរណ៍ផ្លូវគោក ។

ប្រជាពលរដ្ឋម្នាក់ឈ្មោះ *ឌី វីរៈ* ដែលជាអ្នកបើក រថយន្តឈ្នួលពីភ្នំពេញ ទៅខេត្តតាកែវ និងខេត្តកំពត កាត់តាមផ្លូវជាតិលេខ២ និងលេខ៣ បានថ្លែងប្រាប់អ្នកសារព័ត៌មាន កាលពីយប់ថ្ងៃអាទិត្យថា សមត្ថកិច្ចមានឯកសណ្ឋាន ជានគរបាលចរាចរណ៍និងកងរាជអាវុធហត្ថបាននាំគ្នាដាក់ប៉ុស្តិ៍ ចាំជំរិតទារប្រាក់ ពីរថយន្តឈ្នួលដឹកទំនិញ និងអ្នកដំណើរ ដែលបានបើកឆ្លងកាត់ជារៀងរាល់ថ្ងៃនិងមានសកម្មភាពអាក្រក់បំផុត ។ អ្នកបើករថយន្តរូបនេះបានបន្តទៀតថា តាមផ្លូវពីភ្នំពេញ កាត់ខេត្តតាកែវ ឆ្លងទៅខេត្តកំពតមានកុងត្រូលអនាធិបតេយ្យវាំមាន

តទៅទំព័រទី២ ខ

*បរិយាយថ្ងៃនេះ*

## រដ្ឋាភិបាលបក្សប្រជាជនមិនហ៊ានជជែកជាសាធារណៈជាមួយGlobal Witness រឿងបូមខ្សាច់សមុទ្រ

ដោយ : ហង្ស ប្រាជ្ញា

**ការចេញផ្សាយនូវកម្រងឯកសារប្រមូលរៀបរៀងឡើងដោយពួកអ្នកស៊ើបអង្កេតនៃយុទ្ធនាការបរិស្ថានពិភពលោក Global Witness ស្តីអំពីការធ្វើអាជីវកម្មបូមខ្សាច់បាតសមុទ្រខ្មែរដោយក្រុមហ៊ុនរបស់សេដ្ឋីឧកញ៉ាសមាជិកព្រឹទ្ធសភាពីរនាក់របស់គណបក្សប្រជាជនកាន់អំណាច ក៏ដូចជាការចុះ**

តទៅទំព័រទី៤ ក

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០២**
Tel: 017 360 678 , E-mail: kmsnews@gmail.com

**តមកពីទំព័រទី១ ៨**

តែលេចធ្លាយ ជាពិសេសស្ដីពីជនជាតិយួនត្រូវគេចាត់ចែងឱ្យគ្រប់គ្រងសាខានានានៃបណ្ដាញទូរស័ព្ទនេះនៅក្នុងប្រទេសកម្ពុជាហើយដែលករណីខ្លះថ្នាក់គ្រប់គ្រងសាខាមួយចំនួនបានប្រព្រឹត្តរំលោភច្បាប់កម្ពុជាតាមអំពើចិត្តរបស់ពួកគេ ហើយបុគ្គលិកខ្មែរជាអ្នករងគ្រោះ។

ករណីមួយនោះគឺបុគ្គលិកសញ្ជាតិខ្មែរម្នាក់ឈ្មោះ *គៀន ភា* នៃបណ្ដាញក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូនសាខាខេត្តរតនគីរី ត្រូវបានក្រុមហ៊ុននេះគំរាមទារឱ្យបង់លុយ២ពាន់ដុល្លារចំពោះរឿងគ្រោះថ្នាក់ចរាចរកាលពីជាងកន្លះឆ្នាំមុនដែលមានការដោះស្រាយស្រេចបាច់ទៅហើយនោះ។

បុគ្គលិកខ្មែរលោក *គៀន ភា* បាននិយាយថា មានការគំរាមរូបគាត់ពីទីស្ដីការធំនៃក្រុមហ៊ុនមិត្តហ្វូនក្នុងក្រុងភ្នំពេញ ដោយពាក្យរំលឹករបស់ជនរងគ្រោះថា "*ត្រឹមខ្ញុំគេឱ្យតែ១រយដុល្លារឱ្យចាប់ខ្ញុំដាក់គុកភ្លាមឥឡូវក៏បានដែរ* (Sic) "។

នោះគឺជាដំណើររឿងរ៉ាវគ្រោះថ្នាក់ចរាចរតាំងតែពីក្នុងអំឡុងខែវិច្ឆិកាឆ្នាំ២០០៩ ហើយដែលជនជាតិយួន *ង្វៀន ហ៊ូហ្វឹង* ប្រធានសាខាក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូនប្រចាំខេត្តរតនគីរីនៅបន្តអនុវត្តការគាបសង្កត់បង្ខំឱ្យបុគ្គលិកខ្មែរបង់សងលុយ២០០០ដុល្លារទៅឱ្យក្រុមហ៊ុននោះ។ តាមការរៀបរាប់របស់លោក *គៀន ភា* នោះថា កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ជនជាតិយួនឈ្មោះ*ង្វៀនហ៊ូហ្វឹង* ប្រធានសាខាក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូនខេត្តរតនគីរីបានបញ្ជាឱ្យរូបគាត់បើករថយន្តពេញមួយព្រឹក រហូតដល់ថ្ងៃត្រង់ដឹកម៉ាស៊ីនភ្លើងយកទៅដាក់នៅស្រុកអូរយ៉ាដាវ ។គាត់បានបន្តនិយាយទៀតថា ក្រោយពីការដាក់ម៉ាស៊ីនភ្លើងនៅទីនោះហើយ គេក៏បានបញ្ជាឱ្យគាត់បើករថយន្តបង្ហួសទៅដឹកជនជាតិយួន*ង្វៀនហ៊ូហ្វឹង* នោះនៅព្រំដែនវៀតណាម។ ហើយជាគ្រោះថ្នាក់អាក្រក់អ្វីក្នុងពេលកំពុងបំពេញការងារបេសកកម្មតាមបញ្ជារបស់អ្នកចាត់ការនោះ រថយន្តដែលគាត់បានបើកបរក៏ទៅបុកជាមួយរថយន្តយួននៃក្រុមហ៊ុនមួយទៀត។

តាមការរៀបរាប់របស់ *កៀន ភា* នោះថា ក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូននេះបានដោះស្រាយចប់តាំងពេលនោះម្ល៉េះ ហើយមិនគប្បីឡើយដែលមកដល់ពេលនេះ ក្រុមហ៊ុនភាគហ៊ុនធំរបស់យួននេះបែរជាឱ្យគាត់ចេញសងលុយទៅវិញ។

រីឯជនជាតិយួន *ង្វៀន ហ៊ូហ្វឹង* ជាប្រធានសាខាក្រុមហ៊ុនមិត្តហ្វូនប្រចាំខេត្តរតនគីរីបាននិយាយទទួលស្គាល់ថា ពិតជាមានការទាមទារឱ្យ *គៀន ភា* សងនូវលុយ២ពាន់ដុល្លារនោះមែន។ គេបានលើកហេតុផលថា មកពីគាត់បើកឡានលឿនពេក ហើយខុសទាំងស្រុង។

ការគួរឱ្យចាប់អារម្មណ៍មួយនោះវាហាក់បីដូចជាការបំប៉ោងតួលេខយ៉ាងសម្បើមនៅពេលដែលជនជាតិយួន *ង្វៀន ហ៊ូហ្វឹង* បានអះអាងថា ក្រុមហ៊ុនមិត្តហ្វូននេះបានចេញលុយ២ម៉ឺន២ពាន់ដុល្លារសម្រាប់ជួសជុលរថយន្តដែលខូចនោះរួចហើយ។

និយាយអំពីរឿងនេះ ជនជាតិយួនអ្នកចាត់ចែងក្រុមហ៊ុនមិត្តហ្វូនខេត្តរតនគីរី *ង្វៀន ហ៊ូហ្វឹង* បាននិយាយថា ខ្លួនដឹងថាគ្រួសាររបស់បុគ្គលិកខ្មែរ *គៀន ភា*ក្រីក្រក៏ប៉ុន្តែគាត់បានប្រព្រឹត្តខុសដូច្នេះមានករណីយកិច្ចត្រូវតែបង់សំណង។

ចំណែកឯបុគ្គលិកក្រុមហ៊ុនមិត្តហ្វូនផ្សេងទៀតបានអធិប្បាយអំពីការដែលក្រុមហ៊ុននេះ ជាពិសេសជនជាតិយួនដែលគ្រប់គ្រងសាខាខេត្តរតនគីរីនោះថា ការបង្ខំឱ្យបុគ្គលិកខ្មែរ *គៀន ភា*សងនោះជាការរំលោភច្បាប់ការងារទាំងស្រុង ព្រោះហេតុផលថា បុគ្គលិកខ្មែរនេះបើករថយន្តក្នុងបេសកកម្មការងារក្រោមបញ្ជារបស់ក្រុមហ៊ុន។ គាត់បាននិយាយថា ក្រុមហ៊ុននេះគប្បីពិចារណាឡើងវិញនូវការសម្រេចចិត្តរបស់ខ្លួនក្នុងការបង្ខំទារលុយបុគ្គលិកខ្មែរ។

លើសពីនេះទៀត បុគ្គលិកក្រុមហ៊ុនមិត្តហ្វូនបាននិយាយថា ជនជាតិយួន *ង្វៀន ហ៊ូហ្វឹង* ដែលគ្រប់គ្រងសាខាខេត្តរតនគីរីនោះបានរំលោភច្បាប់ការងារកម្ពុជាច្រើនករណីណាស់ក្នុងពេលកន្លងមក។ គាត់បានអធិប្បាយដល់ការដែលជនជាតិបរទេសនេះបានបង្ខំឱ្យបុគ្គលិកខ្មែរធ្វើការហួសម៉ោងកំណត់ និងថែមទាំងបានដេញបុគ្គលិកខ្មែរអស់ច្រើននាក់ទៀតក្នុងរយៈពេលច្រើនខែចុងក្រោយនេះ។

បុគ្គលិកក្រុមហ៊ុនមិត្តហ្វូននេះបាននិយាយថា "*មានការកឹបកេងប្រាក់ខែបុគ្គលិក ការរំលោភសិទ្ធិការងារបុគ្គលិក ដេញចោលទាំងអស់ជាង១០នាក់ហើយ រយៈពេលកន្លះឆ្នាំមកនេះ* "។

ក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូនត្រូវបានទីភ្នាក់ងារព័ត៌មានបរទេសចុះផ្សាយថាគឺជាក្រុមហ៊ុនត្រួតត្រាដោយក្រសួងសង្គ្រាមរបស់រដ្ឋាភិបាលយួនហាណូយក្នុងកិច្ចសហការជាមួយក្រសួងការពារជាតិកម្ពុជា ដោយខាងភាគីវៀតណាមជាអ្នកកាន់ចំណែកភាគហ៊ុនធំ។

ការគួរឱ្យកត់សម្គាល់នោះគឺមានការសាងសង់បង្គោលអង់តែនដល់ខ្ទង់ប្រមាណ១ពាន់៥រយក្នុងទូទាំងប្រទេសកម្ពុជាសម្រប់ប្រតិបត្តិការនេះ ក្រោមការចាត់ចែងរបស់ជនជាតិយួន ដោយមានបុគ្គលិកខ្មែរធ្វើការអម។

ក្នុងអតីតកាលទស្សនាវដ្ដីក្រសួងកងទ័ពរបស់ប្រទេសអង់គ្លេសបានផ្សាយអំពីផ្នែកទូរគមនាគមរបស់កងទ័ពយួនហាណូយចាយលុយទិញឧបករណ៍បច្ចេកវិទ្យាទំនើបពីរគ្រឿងដែលមួយៗតម្លៃ២៥ម៉ឺនដុល្លារពីចក្រភពអង់គ្លេសសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការតាមចាប់សម្លេងចារកម្ម។

ហើយមជ្ឈដ្ឋានខ្មែរដែលគិតបារម្ភដល់អនាគតរបស់ប្រទេសកម្ពុជាចំពោះមុខការវាតទីក្រោមរូបភាពផ្សេងៗរបស់ហាណូយនោះ ក៏បានទិទៀនថា វត្តមានក្រុមហ៊ុនមិត្តហ្វូនមានចំណែកត្រួតត្រាដោយក្រសួងការពារជាតិយួនបើទោះបីជាមានឈ្មោះថា មានភាគហ៊ុនរបស់ក្រសួងការពារជាតិកម្ពុជាក៏ដោយ ក៏នោះវាជារូបភាពមួយនៃការលុកលុយរបស់ឥទ្ធិពលវៀតណាមខាងផ្នែកទូរគមនាគមនេះចង់ឬមិនចង់ក៏វាជាចំណែកមួយនៃការបង្ហាញឥទ្ធិពលរបស់វៀតណាមផ្នែកនយោបាយមកលើរបបគ្រប់គ្រងនៅកម្ពុជាសព្វថ្ងៃនេះដែរ។

ប្រទេសយួនត្រូវគេកត់សម្គាល់ឃើញថាពង្រីកឥទ្ធិពលរបស់ខ្លួនមកលើប្រទេសកម្ពុជាតាមរយៈអំណាចត្រួតត្រាស្រុកខ្មែរដោយគណបក្សប្រជាជនដែលមានទំនាក់ទំនងជិតស្និទ្ធតាំងពីការលើកបន្តុបបង្កើតឡើងដោយកងទ័ពយួនលុកលុយកាន់កាប់កម្ពុជាចំនួនជាង២០ម៉ឺននាក់ពីថ្ងៃ៧មករា១៩៧៩មក។

រដ្ឋាភិបាលគណបក្សប្រជាជនកាន់អំណាច នៃនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ក៏បានផ្ដល់អាជ្ញាប័ណ្ណអាជីវកម្មរុករករ៉ែ ដែលក្នុងនោះក៏មានការកាប់ឈើខ្មែរលក់ដើម្បីនឹងអ្វីដែលគេអះអាងថា វាតដីធ្វើចំការកៅស៊ូរាប់សែនហិកតា ដោយការគ្រប់គ្រងរបស់ក្រុមហ៊ុនយួន ថែមទាំងការផ្ដល់សិទ្ធិឱ្យក្រុមហ៊ុនយួនខ្លះធ្វើអាជីវកម្មរុករករ៉ែប្រេងកាតក្នុងតំបន់ទន្លេសាបខ្មែរប្លុកលេខ១៥ទៀតផង។

នេះគឺជាការអះអាងរបស់លោក *ស៊ាន ប៉េងសែ* ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាមូលដ្ឋានធំនៅទីក្រុងប៉ារីសប្រទេសបារាំង ដែលលោកក៏ជាវិស្វករជំនាញភូព្ទសាស្ត្រខាងខ្មែរហើយយល់ដល់អំពីស្ថានភាពប្រទេសកម្ពុជានោះផងដែរកាលកន្លងទៅថ្មីៗនេះ៕

**តមកពីទំព័រទី១ ៩**

ទេ។

ជាមួយគ្នានេះដែរ ក្រុមគ្រួសារអ្នកនាង *អ៊ិន សុខលីដា* និងអ្នកស្រី *យ៉ា សុខនីម* ដែលជាជនរងគ្រោះដោយសារទឹកអាស៊ីតស្ទើរស្លាប់ស្ទើររស់ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតុលាការនិងក្រសួងមហាផ្ទៃដែលបានពុះពារផ្ដល់នូវភាពយុត្តិធម៌ដល់ក្រុមគ្រួសារគាត់។

យ៉ាងណាក៏ដោយក្រុមគ្រួសារអ្នកស្រី *យ៉ា សុខនីម* បានអំពាវនាវសាជាថ្មីម្ដងទៀតទៅដល់ក្រសួងមហាផ្ទៃដែលមានលោក *ស ខេង* ជារដ្ឋមន្ត្រីនោះ មេត្តាជម្រុញឱ្យមន្ត្រីក្រោមឱវាទគ្រប់ជាន់ថ្នាក់ត្រូវយកអស់ពីសមត្ថភាពដើម្បីស្វែងរកចាប់ខ្លួនលោកស្រី*ជា វដ្ឋា* ជាមេក្លោង និង បក្ខពួកឱ្យបានឆាប់។ ព្រោះបើគិតពីថ្ងៃកាត់ទោសរហូតមកដល់ថ្ងៃម្សិលមិញនេះ ក្រុមឧក្រិដ្ឋជនទាំងនោះស្ថិតក្រៅសំណាញ់ច្បាប់នៅឡើយទេ។

ក្រុមអ្នកតាមដានដំណើររឿងដ៏គួរឱ្យតក់ស្លុតមួយនេះបានសម្ដែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះស្ថាប័នមានសមត្ថកិច្ចដែលហាក់ដូចជាមិនសូវយកចិត្តទុកដាក់នឹងរឿងក្ដីនេះសោះ, ពោលគឺគេទុកឱ្យឧក្រិដ្ឋជនរស់នៅយ៉ាងសុខសាន្តបំផុត។

ប៉ុន្តែគេបានធ្វើការប្រៀបធៀបថា កាលពីតាមចាប់ខ្លួនលោក*ហេង ពៅ* ទោះជាលោករត់ទៅលាក់ខ្លួនដល់ក្រហែងមេឃ, មានមេធាវីបរទេសជួយការពារក្ដីឱ្យយ៉ាងណាក៏ដោយ ក៏សមត្ថកិច្ចនៃប្រទេសកម្ពុជាតាមទៅនាំខ្លួនលោក*ហេង ពៅ* ពីបរទេសយកមកដាក់ពន្ធនាគារព្រៃសនៅស្រុកខ្មែរដែរ។

ដូច្នេះករណីលោកស្រី *ជា វដ្ឋា* និងបក្ខពួកដែលអាជ្ញាធរអះអាងថា កំពុងតែស្វែងរកចាប់ខ្លួននោះ មិនដឹងថាត្រូវចំណាយពេលយូរប៉ុន្មានទៀតទេ។ ហើយអ្វីដែលធ្វើឱ្យក្រុមគ្រួសារជនរងគ្រោះមានការភ័យព្រួយពីសុវត្ថិភាពនោះ គឺវាបណ្ដាលមកពីពួកឧក្រិដ្ឋជន និងមេក្លោងវាកំពុងរស់នៅក្នុងលំហសេរីភាព។

លោក *អ៊ួង វិបុល* ស្វាមីអ្នកស្រី *យ៉ា សុខនីម* ត្រូវបាន The CambodiaDaily ដកស្រង់សម្ដីតាមទូរស័ព្ទយកមកផ្សាយថាបច្ចុប្បន្ននេះលោកកំពុងលាក់ខ្លួនស្របពេលដែលក្រុមគ្រួសារលោកជាង១០នាក់បានដាក់ពាក្យសុំសិទ្ធិជ្រកកោនតាមរយៈ UNHCR ទៅប្រទេសម៉ាឡេស៊ី។

ស្វាមីអ្នកស្រី *យ៉ា សុខនីម* រូបនេះបាននិយាយបន្ថែមទៀតថា "*លុះត្រាណាលោកស្រី ជា វដ្ឋា និងអ្នកសមគំនិតរបស់គាត់ត្រូវបានចាប់ខ្លួនជាមុនសិន, បើមិនអញ្ចឹងទេ ខ្ញុំនៅតែបារម្ភជានិច្ច* "។

លោក*អ៊ួង វិបុល* បានលើកឡើងសារជាថ្មីទៀតថា ក្រុមគ្រួសាររបស់លោកត្រូវទទួលរងការគម្រាមសម្លាប់ជាច្រើនលើកពីលោកស្រី *ជា វដ្ឋា* នៅក្នុងការធ្វើអន្តរាគមន៍អស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីការវាយប្រហារដោយទឹកអាស៊ីតមក។

លោកបានបញ្ជាក់ជាចុងក្រោយថា "*ខ្ញុំកំពុងតែលាក់ខ្លួន, ខ្ញុំមិនចេញក្រៅទេ។ ខ្ញុំត្រូវតែប្រុងប្រយ័ត្ន ព្រោះលោកស្រី ជា វដ្ឋា និងបក្ខពួកគាត់ស្ថិតក្នុងទីងងឹត, ហើយចំណែកខ្ញុំស្ថិតនៅទីកន្លែងភ្លឺ គឺងាយនឹងគ្រោះថ្នាក់ណាស់* "។

គួរបញ្ជាក់ថាកាលពីអំឡុងខែវិច្ឆិកាឆ្នាំ២០០៩សាលាឧទ្ធរណ៍បានកាត់ទោសលោកស្រី *ជា វដ្ឋា* និងអ្នកសមគំនិត៥នាក់ទៀតដែលមួយចំនួនក្នុងចំណោមនោះជាមន្ត្រីប៉ូលិសផងដែរ ។ហើយនៅក្នុងការកាត់ទោសនោះ គឺសាលាឧទ្ធរណ៍កាត់ដោយកំបាំងមុខទៀត ខណៈដែលជនជាប់ចោទកំពុងរស់នៅក្នុងលំហសេរីភាព។

ករណីវាយប្រហារដោយទឹកអាស៊ីតទៅលើអ្នកស្រី *យ៉ា សុខនីម* ត្រូវជាម្ដាយមីងនាង *អ៊ិន សុខលីដា* កាលពីខែឧសភា ឆ្នាំ២០០៨ ត្រូវបានសាលាឧទ្ធរណ៍រកឃើញថា លោកស្រី *ជា វដ្ឋា* អាយុ៤៥ឆ្នាំបានបញ្ជាឱ្យមានការវាយប្រហារដ៏ឃោរឃៅព្រៃផ្សៃនេះ, ពោលគឺបន្ទាប់ពីលោកស្រីអាងខ្លួនមានអំណាច លុយ និងបុណ្យស័ក្តិម្នាក់នេះខឹងក្ដៅក្រហាយនៅពេលដែលនាង *អ៊ិន សុខលីដា* ជាគូស្នេហ៍របស់លោកស្រីព្យាយាមរត់គេចពីទំនាក់ទំនងស្នេហាភេទដូចគ្នា។

ក្រោយការវាយប្រហារដោយទឹកអាស៊ីតទៅលើអ្នកស្រី *យ៉ា សុខនីម* ភ្លាមៗមានសេចក្ដីរាយការណ៍ខ្លះបាននិយាយថា លោកស្រី *ជា វដ្ឋា* នៅទីក្រុងប៉េកាំងប្រទេសចិនប្រជាមានិត។ ប៉ុន្តែមានសេចក្ដីរាយការណ៍ខ្លះទៀតថា លោកស្រី *ជា វដ្ឋា* រត់ទៅសម្ងំលាក់ខ្លួនក្នុងប្រទេសសៀម។

យ៉ាងណាក៏ដោយ អ្វីដែលអាជ្ញាធរប៉ូលិសអន្តរជាតិបានអះអាងប្រាប់កាសែតបរទេសថា ការស្វែងរកលោកស្រី *ជា វដ្ឋា* តាំងពីពេលមានរឿង រហូតមកដល់ពេលនេះត្រូវបានធ្វើឡើងតាមតែសារអ៊ីមែលមួយប៉ុណ្ណោះ។ ហើយចុងក្រោយនេះលោក*កែវ វ៉ាន់ថន* ដែលជាមេប៉ូលិសអន្តរជាតិបាននិយាយគួរឱ្យស្រងាកចិត្តថា "*ខ្ញុំបានអ៊ីមែលទៅប៉ូលិសអាំងទែរប៉ូលថៃ, ប៉ុន្តែខ្ញុំមិនទាន់ទទួលបានការឆ្លើយតបនៅឡើយទេ* "។

លោក *កែវ វ៉ាន់ថន* បានបន្តទៀតថា ប៉ូលិសថៃមិនបានស្វែងរកលោកស្រី *ជា វដ្ឋា* ឱ្យយើងទេ ។ប៉ុន្តែលោកបានបន្ថែមថា លោកមិនបានធ្វើអ្វីឱ្យហួសពីការផ្ញើសារតាមអ៊ីមែលដែលគ្មានការឆ្លើយតបនេះឡើយ។

ដោយឡែកលោក*កែវ វ៉ាន់ថន*បានបង្វែរសំណួរពីការស្វែងរកចាប់ខ្លួនលោកស្រី*ជា វដ្ឋា*និងអ្នកសមគំនិតទៅសួរក្រសួងមហាផ្ទៃវិញ ព្រោះលោកត្រូវបានគេបញ្ជាមិនឱ្យនិយាយរឿងក្ដីនេះទៅកាន់អ្នកកាសែតទេ។

យោងតាមហេតុផលនេះហើយ ទើបក្រុមគ្រួសារអ្នកនាង *អ៊ិន សុខលីដា* និងអ្នកស្រី *យ៉ា សុខនីម* ព្យាយាមអំពាវនាវយ៉ាងទទូចទៅក្រសួងមហាផ្ទៃដែលជាក្រសួងសមត្ថកិច្ចមេត្តាជួយចាប់អ្នកស្រី *ជា វដ្ឋា* ជាមេក្លោង និងបក្ខពួកឱ្យបានក្នុងពេលឆាប់ៗផង។ ម្យ៉ាងទៀតពួកគេសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់តុលាការ និងក្រសួងមហាផ្ទៃហើយដែលផ្ដល់នូវភាពយុត្តិធម៌មកដល់ក្រុមគ្រួសារគាត់នោះ។ ហើយសុំឱ្យតុលាការកំពូលពន្លឿនរឿងក្ដីនេះឱ្យបានលឿនពីព្រោះការកាត់ក្ដីនៅសាលាឧទ្ធរណ៍មិនបានជាទីគាប់ចិត្តដល់ជនរងគ្រោះក៏ដូចជាក្រុមគ្រួសារឡើយ៕

**តមកពីទំព័រទី១ ២**

មិនតិចជាង ពីរកន្លែងនោះទេ ចាំជំរិតយកលុយពីរថយន្តទាំងនោះ ។ ក្នុងមួយកន្លែងយកពី ៣-៥ពាន់រៀល ហើយសមត្ថកិច្ចបានប្រើពាក្យសម្ដីនិងកាយវិការក្រអឺតក្រទមដូចជាពុំមានសីលធម៌នោះទេ។ គាត់បញ្ជាក់យ៉ាងដូច្នេះថា"*មានច្បាប់ក៏យកលុយ អាអត់ច្បាប់ ក៏យកលុយ ហើយឡានរត់ឈ្នួលហ្នឹង អាសំពីងសំពោង ក៏យកលុយមិនសំពីងសំពោង ក៏យកលុយ. អនុសាសន៍សម្ដេចឱ្យបំបាត់កុងត្រូលជជុះហ្នឹងក៏ប៉ុន្តែនៅតែមានកើតឡើងតាមផ្លូវយើងហ្នឹង មិនដឹងជាយ៉ាងម៉េច ។ហើយឃើញតែប្រចាំថ្ងៃរាល់តែថ្ងៃ* "។

ទាក់ទិន នឹងបញ្ហាកុងត្រូលជជុះនេះដែរបុរសឈ្មោះ *ឈួក លាប* ដែលជាអ្នកបើករថយន្តឈ្នួលដែរនោះ បានរអ៊ូរទាំថាកុងត្រូលជជុះមួយកន្លែង ដែលស្ថិតនៅផ្លូវជាតិលេខ៧ នៅក្នុងចំណុចផ្លូវកែងឆ្លងដែលស្ថិតនៅស្រុកឆ្លូងខេត្តក្រចេះ ។ សមត្ថកិច្ចនគរបាល និងកងរាជអាវុធហត្ថបានដាក់ប៉ុស្តិ៍ជំរិតយកលុយពីរថយន្តដឹកអ្នកដំណើរ ចាប់ពីមួយម៉ឺនរៀល ទៅមួយម៉ឺនប្រាំពាន់រៀល ក្នុងមួយគ្រឿង ។ គាត់បានបន្តទៀតថា គាត់សូមសំណូមពរដល់លោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ពិនិត្យមើលសកម្មភាពកុងត្រូលជជុះ ដែលបានរៀបរាប់ខាងលើមកនេះ ។ ព្រោះលោក*ហ៊ុន សែន* ធ្លាប់បានប្រកាស កាលពីឆ្នាំ២០០៨កន្លងមក ប៉ុន្តែបច្ចុប្បន្ននេះបានកើតមានជាថ្មីម្ដងទៀត។បុរសរូបនេះ បានបញ្ជាក់យ៉ាងដូច្នេះថា "*សម្ដេច បានប្រកាសមួយសារពីរសារហើយមិនដឹងយ៉ាងម៉េចបានគេមិនព្រមស្ដាប់* "។

ចំណែក ឯបុរសអ្នកបើករថយន្តឈ្នួលដែរនោះដែលរស់នៅស្រុកកៀនស្វាយ បានត្អូញត្អែរថា នៅតាមផ្លូវជាតិលេខ១ចាប់ពីគល់ស្ពានច្បារអំពៅ ទៅដល់កំពង់ចម្លងអ្នកលឿង កុងត្រូលជជុះក្រោម ស្លាកពិនិត្យពន្ធយានយន្ត មិនតិចជាងបីកន្លែងនោះទេ។ ពួកប៉ូលិសទាំងនោះចាំស្ទាក់យកលុយពី រថយន្តក្នុងមួយគ្រឿង ចាប់ពីបីពាន់រៀលទៅប្រាំពាន់រៀលដែលមិនអាចតថ្លៃបាន ។

អ្នកបើកបររូបនេះក៏បានស្នើលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បើកការស៊ើបអង្កេត ដើម្បីលុបបំបាត់សកម្មភាពកុងត្រូលជជុះបែបអនាធិបតេយ្យនេះ ឡើងវិញ ។

មិនថាតែអ្នកបើកបររថយន្តឈ្នួលនោះទេ ដែលរិះគន់នឹងទង្វើ របស់មន្ត្រីកុងត្រូលជជុះទាំងនោះ សូម្បីតែមន្ត្រីរាជការ និងប្រជាពលរដ្ឋ ដែលរស់នៅស្ទើរតែ ទូទាំងប្រទេសកម្ពុជានោះ ក៏បានត្អូញត្អែរដូចគ្នាផងដែរ ពីភាពអនាធិបតេយ្យ នៃកុងត្រូលជជុះទាំងនោះ។

បុរសម្នាក់ ដែលជាមន្ត្រីរាជការបំរើការនៅខេត្តស្វាយរៀង

**តទៅទំព័រទី៣ ២**

**តមកពីទំព័រទី១ ឡ**

ជ្រើសរើសពលករពលការិនីឱ្យទៅបំរើការនៅក្រៅប្រទេស។

ក្រុមហ៊ុនខ្លះ ក៏ត្រូវបាន គេស្គាល់អត្តសញ្ញាណ យ៉ាងច្បាស់ទៀតផង ដែលបានបោកប្រាស់ពលករ ពលការិនីខ្មែរ យកទៅលក់អោយឈ្មួញបរទេសធ្វើជាទាសករ ដោយមិនគោរព លក្ខខណ្ឌការងាររបស់ខ្លួនដែលមានជាមួយពលករពលការិនីដូចជាក្រុមហ៊ុន Equine Resources (Cambodia)Co.,Ltdជាដើម។

ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុននេះ លោក*ម៉ៅ មុនីវណ្ណ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលកំពង់ចាម កាលពីថ្ងៃទី២៤ ឧសភា ឆ្នាំ២០១០ កន្លងទៅ បានសរសេរលិខិត ផ្លូវការមួយ ស្នើអោយលោក*វង សូត* រដ្ឋមន្ត្រី ក្រសួងការងារជួយធ្វើអន្តរាគមន៍ ។

លិខិតបានសរសេរថា កាលពីថ្ងៃទី១២ ខែឧសភា ២០១០ ខ្ញុំបានទទួលបណ្តឹងផ្ទាល់មាត់ ពីក្រុមគ្រួសារ ពលករ និងពលការិនីទៅបំរើការ នៅប្រទេសម៉ាឡេស៊ី ដែលធ្វើការជ្រើសរើស ដោយក្រុមហ៊ុន Equine Resources (Cambodia) Co., Ltd ដែលស្នើសុំ ឱ្យអ្នកតំណាងរាស្ត្រជួយអន្តរាគមន៍ ទៅស្ថាប័នមានសមត្ថកិច្ច អោយជួយដោះស្រាយ រវាងពលករ និងពលការិនីជាមួយក្រុមហ៊ុន ។

លោក*ម៉ៅ មុនីវណ្ណ* បានបន្តនៅក្នុងលិខិតនោះទៀតថាតាមការបញ្ជាក់អះអាង របស់ពលករ និងពលការិនី អោយដឹងថាក្រុមហ៊ុន មិនបានគោរព ទៅតាមលក្ខខណ្ឌ ដូចមានចែងនៅក្នុងសេចក្តីជូនដំណឹងជ្រើសរើសពលករ និងពលការិនី ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី របស់ខ្លួនឡើយ ហើយថែមទាំងក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលបន្ថែមម៉ោងធ្វើការ ជារៀងរាល់ថ្ងៃ, ដកលិខិតឆ្លងដែន របស់ពលករពលការិនីជាដើម ។

ជាមួយគ្នានោះដែរ លោក*ម៉ៅ មុនីវណ្ណ* ក៏បានផ្តល់ជូនទៅក្រសួងការងារ នូវលក្ខខណ្ឌនៃការជ្រើសរើសពលករ និងពលការិនី របស់ក្រុមហ៊ុននេះ មួយច្បាប់ផងដែរ ព្រមទាំង បញ្ជីរាយឈ្មោះ របស់ពលករ ពលការិនីទៀតផង ។

ទង្វើបែបនេះរបស់ក្រុមហ៊ុនគឺផ្ទុយទៅនឹងគោលការណ៍នានានៃសេចក្តីជូនដំណឹង ជ្រើសរើសពលករ និងពលការិនី ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ច្បាប់ស្តីពីការងារ និងច្បាប់នានា នៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យដូចបាន ជំរាបជូនខាងលើនេះ អ្នកតំណាងរាស្ត្រ*ម៉ៅ មុនីវណ្ណ* ស្នើលោក *វង សូត* ពិនិត្យ និងចាត់វិធានការជម្រុញអោយក្រុមហ៊ុន Equine Resources (Cambodia) Co., Ltd នេះអនុវត្តនូវគោលការណ៍របស់ខ្លួន ក្នុងការជ្រើរើសពលករ និងពលការិនី ទៅបំរើការនៅប្រទេសម៉ាឡេស៊ីអោយបានត្រឹមត្រូវដើម្បីការពារ ផលប្រយោជន៍ពលករយើង ក្នុងក្របខណ្ឌច្បាប់ការងារ ដោយក្តីអនុគ្រោះ ៕

**តមកពីទំព័រទី១ ញ**

ថ្ងៃទី២៤ ខែឧសភា ម្សិលមិញ លោក *ជា ចំរើន* បានចូលខ្លួនទៅបំភ្លឺ និងបង្ហាញនូវភស្តុតាងសម្រាប់ដាក់បន្ទុកទៅលើស្ត្រី*អ៊ឹងវិទ្ធា*តាមផ្លូវច្បាប់រួចហើយ ។

យើងគួរបញ្ជាក់ផងដែរថា នៅក្នុងដំណើររឿងក្តីនេះក៏មានឈ្មោះលោក *នី ហេង* ដែលជាអតីតស្វាមីស្ត្រី *អ៊ឹង វិទ្ធា* ក៏ជាជនដែលត្រូវចោទដោយតុលាការក្រោមបទរំលោភសេចក្តីទុកចិត្តផងដែរ ។ ព្រោះមានឯកសារជាច្រើនដែលពាក់ព័ន្ធនឹងស្ត្រី *អ៊ឹង វិទ្ធា* ខ្ចីប្រាក់លោក *ជា ចំរើន* និងភរិយាលោកនោះ សុទ្ធតែមានសំណៅស្នាមមេដៃរបស់លោក*នី ហេង*និងស្ត្រី *អ៊ឹងវិទ្ធា*។

កន្លងមកនេះ សាលាដំបូងរាជធានីភ្នំពេញបានចេញដីការក្សាការពារទីតាំងវិនិយោគផ្សារចំនួន៦កន្លែងបន្ទាប់ពីលោក *ជា ចំរើន* បានដាក់ពាក្យបណ្តឹងប្តឹងស្ត្រី *អ៊ឹង វិទ្ធា* ពីបទរំលោភសេចក្តីទុកចិត្ត និងក្លែងលិខិតសាធារណៈ ។

ទីតាំងវិនិយោគផ្សារទាំង៦កន្លែងនោះក៏ធ្លាប់មានបញ្ហាយ៉ាងចម្រូងចម្រាសជាមួយអាជ្ញាធរថ្នាក់ខេត្តផងដែរ ដូចជាខេត្តតាកែវ, ខេត្តក្រចេះជាដើម ដោយសារការវិនិយោគរបស់ស្ត្រី *អ៊ឹង វិទ្ធា* មិនគោរពទៅតាមគោលការណ៍វិនិយោគ។

ដីការក្សាការពារទីតាំងវិនិយោគផ្សារទាំង៦កន្លែងដែលសាលាដំបូងរាជធានីភ្នំពេញធ្វើឡើងនោះរួមមាន លិខិតលេខ ៥៩៥៥ សហវ.តរ ចុះថ្ងៃទី០៧ ខែវិច្ឆិកាឆ្នាំ២០០៨របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានជំរាបជូនអភិបាលខេត្តក្រចេះ។ លិខិតលេខ១៥៨៨ សហវ.តរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជំរាបជូនអភិបាលខេត្តកោះកុង។

នៅមានលិខិត៤ទៀតដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជំរាបជូនអភិបាលខេត្តតាកែវ, ខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំង។ ពោលគឺទីតាំងវិនិយោគផ្សារទាំង៦កន្លែងនេះមិនអនុញ្ញាតឱ្យជនណាម្នាក់យកទៅធ្វើអាជីវកម្មឡើយ រហូតមានសេចក្តីសម្រេចជាថ្មីពីតុលាការ ។

ដោយឡែកបើយោងតាមប្រភពស្និទ្ធនឹងលោក *ជា ចំរើន* បានឱ្យដឹងថា នៅថ្ងៃទី២៧ ខែឧសភាខាងមុខ លោក*ជា ចំរើន* នឹងប្តឹងដាក់បន្ទុកទៅលើជនជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌថែមទៀត ដែលស្មើនឹងមានន័យថា លោក *ជា ចំរើន* មិនដកថយ ឬផ្តល់ឱកាសឱ្យខ្លារត់ចូលព្រៃវិញបានជាដាច់ខាត ។

មុននេះបន្តិចមានការភ្ញាក់ផ្អើលនៅពេលដែលលេចឮថាមានអ្នករត់ការបានរិះរកគ្រប់មធ្យោបាយដើម្បីដោះលែងជនជាប់ចោទ *អ៊ឹងវិទ្ធា*ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន។ ប៉ុន្តែមធ្យោបាយដ៏គម្រក់នោះត្រូវទទួលរងនូវការបរាជ័យយ៉ាងអាម៉ាស់បំផុត។

ចំពោះដំណើររឿង នៃការជំពាក់ប្រាក់រវាងស្ត្រី *អ៊ឹង វិទ្ធា* ជាមួយលោក *ជា ចំរើន* និងភរិយារបស់លោកនោះ គឺមានឯកសារជាច្រើនដែលមានលក្ខណៈពេញលេញខាងផ្លូវច្បាប់ ដែលអាចឱ្យតុលាការដាក់បន្ទុកទៅលើស្ត្រី *អ៊ឹងវិទ្ធា*និងអតីតស្វាមីឈ្មោះ *នី ហេង* បាន។

ខាងក្រោមនេះដើម្បីបង្ហាញជាភស្តុតាងយើងសូមចុះផ្សាយនូវលិខិតប្រគល់-ទទួលប្រាក់តាមខ្លឹមសារដើមទាំងស្រុង៕


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតប្រគល់_ទទួលប្រាក់

នាងខ្ញុំ **អ៊ឹង វិទ្ធា** អាយុ ៤៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤០០៣៨៦៦៦ មានទីលំនៅភូមិថ្មស ឃុំថ្មស ស្រុកបុទុមសាគរ ខេត្តកោះកុង ជាភាគីអ្នកខ្ចីប្រាក់បានទទួលប្រាក់ចំនួន **១,០៩០,៥០០ដុល្លាអាមេរិក(មួយលានប្រាំបួនម៉ឺនប្រាំរយដុល្លា អាមេរិក)** ពី លោក **ជា ចំរើន** អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ២០ + ២០Zផ្លូវលេខ៤០៦ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាភាគីម្ចាស់ប្រាក់ គ្រប់ចំនួនពិតប្រាកដមែន ។

- ធ្វើនៅភ្នំពេញ,ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០

**ស្នាមមេដៃស្តាំ**

| **ភាគីអ្នកខ្ចីប្រាក់** | **ភាគីម្ចាស់ប្រាក់** |
| --- | --- |
| អ៊ឹង វិទ្ធា | ជា ចំរើន |

**បានឃើញ**



មេធាវី.ណាច_ទ្រី

**តមកពីទំព័រទី២ ខ**

បានមានប្រសាសន៍ អោយដឹងថា លោកបានឃើញសកម្មភាពយ៉ាងអនាធិបតេយ្យ របស់កុងត្រូលជជុះដែលជ្រកក្រោមប៉ុស្តិ៍ត្រួតពិនិត្យច្បាប់ចរាចរណ៍ បានកើតមានពីបីទៅបួនកន្លែង នៅតាមខ្សែក្រវ៉ាត់ នៃសាលាខេត្តស្វាយរៀង, តែមិនដែលឃើញមានមន្ត្រីផ្នែកណាមួយបង្ក្រាបឬក៏ទប់ស្កាត់នោះឡើយ ។

មន្ត្រីរាជការរូបនេះ បានស្នើទៅមន្ត្រីដឹកនាំខេត្តអោយស្តាប់ និងត្រូវអនុវត្តន៍ តាមបទបញ្ជារបស់លោក*ហ៊ុន សែន* ដែលជាប្រមុខដឹកនាំរដ្ឋាភិបាល ស្តីអំពីការលុបបំបាត់ កុងត្រូលជជុះអនាធិបតេយ្យ តាមផ្លូវសាធារណៈ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ បើមិនដូច្នោះទេ វាជាការប្រមាទមួយ ដល់ថ្នាក់ដឹកនាំប្រទេសហើយ ។

បើតាម ការអះអាងពីប្រជាពលរដ្ឋ ស្តីអំពីកុងត្រូលជជុះដែលបានកើតឡើង ជាច្រើនកន្លែង នៅតាមបណ្តាខេត្តនានានោះប៉ុន្តែសម្រាប់ថ្នាក់ដឹកនាំនៅតាមបណ្តាខេត្ត ទាំងនោះ បានបដិសេធ និងច្រានចោលដោយបកស្រាយថាមិនមានកុងត្រូលជជុះច្រើនកន្លែងដូចជាការចោទប្រកាន់របស់ប្រជាពលរដ្ឋ និងអ្នកបើករថយន្តឈ្នួលទាំងនោះទេ ។គឺមានតែប៉ុស្តិ៍ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ ផ្លូវគោកមួយចំនួនតែប៉ុណ្ណោះ។

គួរបញ្ជាក់ដែរថា លោក*ហ៊ុន សែន* ធ្លាប់បាន មានបទបញ្ជាពីរដងរួចមកហើយ ស្តីអំពីកុងត្រូលជជុះនេះដោយលោកបានឱ្យមន្ត្រីក្រោមឱវាទ តាមខេត្តក្រុង ឱ្យពិនិត្យមើលផ្លូវ ប៉ុន្តែសកម្មភាពកុងត្រូលជជុះនៅតែមិនអាចទប់ស្កាត់បានដដែល ។

កាលពីខែមេសា កន្លងទៅ លោក*ហ៊ុន សែន* បានរំលឹកជាថ្មីម្តងទៀត ទៅមន្ត្រីក្រោមឱវាទឱ្យពិនិត្យមើល កុងត្រូលជជុះដែលនៅតាមផ្លូវដែលជាការលំបាកធ្វើដំណើរ របស់ប្រជាពលរដ្ឋ ។ ហើយការប្រកាសបែបនេះ បានធ្វើអោយប្រជាពលរដ្ឋមានការអប់អរសាទរ ចំពោះអនុសាសន៍ របស់លោក *ហ៊ុន សែន* នោះ។

លោក*ហ៊ុន សែន* បានថ្លែងថា "*កុងត្រូលជជុះវាកើតឡើងវិញហើយ អស់លោកខេត្ត ។ កុងត្រូលជជុះ វាបានកើតឡើងវិញហើយវាកើតនេះវាមិនត្រឹមតែពិនិត្យសត្វស៊ីអី ក៏វាពិនិត្យទាំងអស់ ខ្ញុំបានឮការត្អូញត្អែរ និងបានមើលព័ត៌មានខ្លះ ហើយក៏មើលទូរទស្សន៍ខ្លះដែរអំពីការថតយកដែលគេហៅថា អាកុងត្រូលជជុះវាកើតឡើងវិញហើយកើតឡើងវិញ ឱ្យអស់លោកមើលផ្លូវ មើលផ្លូវអារឿង កុងត្រូលជជុះហ្នឹង តើយើងមនុស្សបួនដប់លាននាក់ហ្នឹងនៅឃ្វាលមនុស្សខូចប៉ុន្មាន នាក់ហ្នឹងដល់ណាទៀត*" ។

ទោះបីជា លោក*ហ៊ុន សែន* បានស្រែកបញ្ជាក្តែងៗតាមទូរទស្សន៍ និងវិទ្យុ ដែលឱ្យមន្ត្រីក្រោមឱវាទរបស់លោកលុបបំបាត់កុងត្រូលជជុះ ក៏ប្រជាពលរដ្ឋភាគច្រើន បាននាំគ្នានិយាយថា វាគ្មានប្រសិទ្ធិភាពអ្វីបន្តិចនោះទេ ហើយថា គ្មានមន្ត្រីនៅខេត្តក្រុងណាមួយ បានយកត្រចៀកស្តាប់ឬយកភ្នែកមើលនិងអនុវត្តន៍បទបញ្ជា របស់លោកឱ្យមានប្រសិទ្ធភាពឡើយ។ វាផ្ទុយទៅវិញ កុងត្រូលជជុះទាំងនោះ កាន់តែ មានច្រើនឡើងដដែល នៅតាមបណ្តាខេត្តក្រុងមួយចំនួនហើយធ្វើឱ្យប្រជាពលរដ្ឋធ្វើដំណើរពិបាកដដែល ។

ឥឡូវកុងត្រូលជជុះ ដែលកើតចេញពីអាជ្ញាធរ ក្រោមឱវាតលោក*ហ៊ុន សែន* កំពុងប្រឆាំង នឹងបញ្ជាលោក*ហ៊ុន សែន* ហើយ ៕

**តមកពីទំព័រទី៤ ឧ**

ពេលនោះកម្ពុជាត្រូវតែនិយាយឱ្យច្បាស់លាស់ ម៉ឺងម៉ាត់ថា ថៃឈ្លានពានកម្ពុជា ហើយត្រូវតែដកទ័ពចេញ ដោយឯកតោភាគី គ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

ប៉ុន្តែផ្ទុយទៅវិញ រដ្ឋាភិបាលបែរជាព្រមព្រៀង ឱ្យថៃរក្សាចំនួនទ័ពស្មើគ្នា ឈរជើង នៅវត្តកែវសិក្ខាគីរីស្វារៈ ហើយនៅចំណុចផ្សេងទៀត ក៏នៅតែមិនទាន់តម្រូវឱ្យថៃ ដកថយ ទៅកាន់មុនចំណុច ដែលបានកើតហេតុនោះដែរ ។

ភាគីសៀម បាននិយាយផ្លូវការក្នុងគោលបំណងមិនអោយភាគីកម្ពុជា ជួសជុល វត្តកែវសិក្ខាគីរីស្វារៈនេះទេ ដោយគេអះអាងថា វត្តនោះស្ថិតនៅលើទឹកដីរបស់ខ្លួន ។

បញ្ហានេះលោក*គង់ គាំ* បានមានប្រសាសន៍ថា "*ខ្ញុំគិតថា ជំហរ និងអកប្បកិរិយា របស់រាជរដ្ឋាភិបាល និងទ័ពយើង មិនម៉ឺងម៉ាត់ មិនមានវិធានការ អ្វីមួយឱ្យពិតប្រាកដ,ធ្វើលំៗរឿងវត្តកែវសិក្ខាគីរីស្វារៈ... ទៅជួបជុំគ្នា ស៊ីផឹកជាមួយគ្នា*" ។

លោក*គង់ គាំ* បានបញ្ជាក់ថា យើងមិននិយមសង្គ្រាមមិននិយាយ អំពីរឿងប្រើកម្លាំងទេ គឺយើងប្រើច្បាប់អន្តរជាតិ និងប្រាប់អង្គការសហប្រជាជាតិថា ថៃបានឈ្លានពានយើង ។

លោកបានមានប្រសាសន៍ថា "*យើងមិននិយម ធ្វើសង្គ្រាមឬនិយមប្រើកម្លាំងទេ ។ប៉ុន្តែខ្ញុំថា អប្បកិរិយាជំហរ និងអំពើបែបហ្នឹងជាអំពើជាកាយវិការដែលទទួលស្គាល់ថាថៃអាចឈរជើងនៅលើអធិបតេយ្យភាព បូរណភាពទឹកដីខ្មែរ ដោយគ្មានវិធានការច្បាស់លាស់ទេ* " ។

លោក*គង់ គាំ* ក៏បានចង្អុលផ្លូវអោយរដ្ឋាភិបាលដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសថៃ ថា "*ព្រំដែនខាងលិច ក៏មានបញ្ហា ព្រំដែនខាងកើត ក៏មានបញ្ហាសុទ្ធតែជាបញ្ហាជាក់ស្តែងទាំងអស់ ។ ជាក់ស្តែងត្រង់ថា រាជរដ្ឋាភិបាលបណ្តោយអោយប្រទេសជិតខាង គេមើលងាយយើង, ហើយទន្ទ្រាន មកលើបូរណភាព អធិបតេយ្យភាពជាតិយើង ។ ជំហរយើងគឺត្រូវតែប្រើប្រាស់ អង្គការអន្តរជាតិ សមត្ថកិច្ចអន្តរជាតិ ដើម្បីដោះស្រាយបញ្ហា បូរណភាពទឹកដីហ្នឹង, មិនអាចធ្វើទ្វេភាគីគ្មានកោះគ្មានត្រើយ គ្មានគោលជំហរអីច្បាស់លាស់អញ្ចឹងទេ*"។

លោក*គង់ គាំ* បានបន្តទៀតថាការដោះស្រាយបញ្ហាព្រំដែនទាំងខាងលិចទាំងខាងកើតល្មមដល់ពេល ដោះស្រាយ ដោយក្រុមប្រឹក្សាសន្តិសុខ របស់អង្គការសហប្រជាជាតិហើយ ។

ជាមួយគ្នានោះដែរ លោក*គង់គាំ*បានថ្លែងក្នុងនាមទស្សនផ្ទាល់ខ្លួនថា ភាគីវៀតណាម ក៏ទំនងជាទទួលស្គាល់ថាការបោះបង្គោលព្រំដែន ចូលក្នុងទឹកដីកម្ពុជា នៃបង្គោលលេខ ១៨៤, ១៨៥, ១៨៦ និងលេខ១៨៧ នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង ហើយ ដោយសារតែ ចាប់តាំងពីលោក*សម រង្ស៊ី* ដឹកនាំចលនាអ្នកភូមិទៅដកតម្រុយបង្គោលព្រំដែន លេខ១៨៤មក បានធ្វើឱ្យយួន ដកគ្រឹះបង្គោលព្រំដែនលេខ១៩៤, លេខ១៨៦ និងលេខ១៨៧យកទៅស្រុកគេវិញទាំងអស់ ។

ទោះបីយ៉ាងណា មន្ត្រីរដ្ឋាភិបាលតែងនិយាយថា ការបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាងនោះ មិនបានធ្វើអោយកម្ពុជាបាត់បង់ទឹកដីទេ បើទោះបីជា ប្រជាពលរដ្ឋជាសាក្សីរស់បញ្ជាក់ថា ពួកគាត់បានបាត់បង់ដីស្រែ ដោយសារតែ ការបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាង ជាពិសេស ជាមួយប្រទេសយួនក៏ដោយ ។

បញ្ហានេះហើយ បានជាថ្នាក់ដឹកនាំគណបក្សសម រង្ស៊ី ថ្លែងថា រដ្ឋាភិបាលគ្មានជំហរច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងនោះ ៕

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ និងមានលក់ម៉ាស៊ីន បញ្ចាំងខ្សែភាពយន្ត ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

តមកពីទំព័រទី១ ម

ហើយហៅអ្នកដឹកនាំរបស់អង្គការនេះថាឆ្កួតជ្រូក និងមានជម្ងឺផ្លូវចិត្តឬហៅថាជារបាយការណ៍សំរាម ។

ពាក្យសម្តីគ្រោតគ្រាតរបស់មន្ត្រីរដ្ឋាភិបាលនេះ បានធ្វើឱ្យលោក*គង់ គាំ* ប្រធានស្តីទីគណបក្សសម រង្ស៊ី មានប្រសាសន៍ថាប្រហែលលោក*ហោណាំបូរ៉ា*ឯកអគ្គរាជទូតខ្មែរ ប្រចាំនៅប្រទេស អង់គ្លេសឆ្កួតជ្រូក ឬអង្គការ Global Witness ឆ្កួតជ្រូក?

ភាពតានតឹង ដោយសង្គ្រាមពាក្យសម្តីរវាងអង្គការ Global Witness ជាមួយកម្ពុជានោះ គឺការចេញរបាយការណ៍របស់អង្គការមួយនេះកាលពីសប្តាហ៍មុន ដែលថា ឧកញ៉ា*ម៉ុង ឫទ្ធី* និង ឧកញ៉ា*លី យ៉ុងផាត់* សមាជិកព្រឹទ្ធសភា គណបក្សប្រជាជនទទួលបានអាជ្ញាប័ណ្ណស្ងាត់ៗ ពីរដ្ឋាភិបាល ដើម្បីបូមខ្សាច់ខ្មែរយកទៅលក់ឱ្យប្រទេសសិង្ហបុរី តម្លៃ រាប់រយលានដុល្លារ ក្នុងមួយឆ្នាំៗ ។ ឧកញ៉ាទាំងពីររូបដែលស្និទ្ធ នឹងលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដូចគ្នានេះមានម្នាក់ គឺឧកញ៉ា*ម៉ុង ឫទ្ធី* បានបដិសេធ ។

ក្រោយមកមានសេចក្តីរាយការណ៍ថា លោក*ហោ ណាំបូរ៉ា* យល់ព្រម ឆ្លើយតប ជាសាធារណៈ ជាមួយអង្គការ Global Witness នៅកន្លែងអព្យាក្រឹត្យណាមួយ ដើម្បីជួយលុបលាងមុខមាត់ របស់អ្នក ដែលមានឈ្មោះក្នុងរបាយការណ៍Global Witness ។

ប៉ុន្តែកាលពីថ្ងៃទី២១ឧសភា ឆ្នាំ២០១០ ស្ថានទូតកម្ពុជា ប្រចាំទីក្រុងឡុងដ៍ នៃប្រទេសអង់គ្លេស បានសម្រេចចិត្ត មិនធ្វើការពិភាក្សាដេញដោលជាមួយអង្គការ Global Witness ទេ និងថា មានជម្ងឺឆ្កួត និងជម្ងឺផ្លូវចិត្ត ។

លោក*គង់ គាំ* បានមានប្រសាសន៍ថា "*ខ្ញុំកោតសរសើរហោណាំបូរ៉ាថាគាត់មានគំនិតហើយ Global Witness ក៏យល់ស្របថា នឹងទទួលចាត់ចែង អោយមានការជជែកចំហតទល់គ្នា ។ ប៉ុន្តែប្រហែលហោ ណាំបូរ៉ា ធ្វើដោយឯកចិត្ត គឺផ្ទុយ ពីបន្ទាត់នយោបាយរបស់រដ្ឋាភិបាលនៅឯភ្នំពេញ, គាត់ក៏ត្រូវក្រឡាស់វិញ ។ដូច្នេះខ្ញុំមើលឯកសារថ្ងៃនេះ ព័ត៌មានថ្ងៃនេះ ហោ ណាំបូរ៉ាថា Global Witness នោះឆ្កួតជ្រូក ។ ខ្ញុំមិនដឹងថា ហោណាំបូរ៉ា ឆ្កួតជ្រូកនោះទេ គឺពីរនាក់ហ្នឹងមានម្នាក់ឆ្កួត និងម្នាក់អត់ឆ្កួតហើយ*" ។

លោក*គង់ គាំ* បានមានប្រសាសន៍ ពាក់ព័ន្ធ នឹងពាក្យឆ្កួតជ្រូកនេះ យ៉ាងដូច្នេះថា "*ប៉ុន្តែខ្លួនខ្ញុំ កត់សំគាល់ឃើញថា រដ្ឋាភិបាលសព្វថ្ងៃនេះ ចូលចិត្ត ប្រតិកម្ម និងប្រឈម ជាមួយនឹងលោកខាងលិចជាមួយអង្គការសហប្រជាជាតិ ជាមួយលោកយ៉ាស្ហូ ហ្កាយ អតីតតំណាងពិសេស ទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា, ជាមួយ UNDP ជាមួយ ធនាគារពិភពលោក, ជាមួយនឹង របាយការណ៍ សព្វបែបយ៉ាងរបស់Global Witness ទាំងអស់ ។ ផ្ទុតគំនិតរបស់គេគឺប្រទូស្តរាយជាមួយនឹងលោកខាងលិច ។ប៉ុន្តែជាមួយនឹងពួកចិន ពួកវៀតណាមវិញ គឺថាគេបណ្តោយ គេគ្មានប្រតិកម្ម អ្វីទាំងអស់*" ។

មតិនានា ក៏យល់ឃើញ ដូចលោក*គង់គាំ* ដែរថារដ្ឋាភិបាលកម្ពុជា ខ្លាចណាស់ ចំពោះការបកស្រាយ លាតត្រដាង រវាងមន្ត្រីរដ្ឋាភិបាល ជាមួយអង្គការឯករាជ្យជាតិ អន្តរជាតិនានាឱ្យសាធារណៈជនដឹងនោះ ។

លោក*គង់ គាំ* បានមានប្រសាសន៍ថា "*ហោ ណាំបូរ៉ា បានប្តូរឥរិយាបថវិញ ក៏ដោយសាររដ្ឋាភិបាលភ្នំពេញ ។ដូច្នេះខ្ញុំថារដ្ឋាភិបាលភ្នំពេញ មិនហ៊ានទៅតទល់ ជាមួយអង្គការ Global Witness នៅកន្លែង ឯករាជ្យមួយទេ...ដូច្នេះ ខ្ញុំគិតថា បញ្ហានេះគួរអោយសោកស្តាយហើយ បញ្ហាជាក់ស្តែង,ការរកស៊ីខ្សាច់ពិសេសខ្សាច់ នៅខេត្តកោះកុងយកទៅលក់ នៅសិង្ហបូរីនេះ, ខ្ញុំគិតថា សិង្ហបូរី គេទទួលខុសត្រូវ*" ។

គួរបញ្ជាក់ថា កាលពីពេលថ្មីៗនេះ ស្ថានទូតកម្ពុជាបានប្រកាស នៅតាមវិបសាយ របស់ខ្លួនថាលោក*ហោ ណាំបូរ៉ា* បានអញ្ជើញមន្ត្រី អង្គការ Global Witness ទៅពិភាក្សា ដេញដោលនៅទីក្រុងឡុងដ៍ឬកន្លែងផ្សេង, ហើយថា អង្គការនេះនឹងត្រូវជម្រុញឱ្យពន្យល់ អំពីយុទ្ធនាការបង្ខូចកេរ្តិ៍ឈ្មោះ និងសំអប់រដ្ឋាភិបាល ។ ចំណែកឯអង្គការ Global Witness ក៏បានឆ្លើយតបភ្លាមៗដែរថា ខ្លួនបានទទួលយកការអញ្ជើញនេះ ។

ទោះជាយ៉ាងណា ក្នុងលិខិតមួយ កាលពីថ្ងៃទី២១ ឧសភា ឆ្នាំ២០១០ លោក*ឃុន សុវណ្ណណែត*ប្រធានការិយាល័យរបស់លោក*ហោ ណាំបូរ៉ា* នៅទីក្រុងឡុងដ៍បាននិយាយថា ឯកអគ្គរាជទូតរូបនេះ លែងត្រៀមខ្លួនដើម្បីចូលរួមកិច្ចពិភាក្សា ដេញដោលជាសាធារណៈទៀតហើយ និងក៏បាន ចោទអង្គការនេះដែរ ថា មានរបៀបវារៈបែបនយោបាយ ក្នុងការបង្ខូចឈ្មោះ រដ្ឋាភិបាល ។ នេះបើតាមការ ចុះផ្សាយរបស់ The Cambodia Daily កាលពីថ្ងៃទី២៤ ឧសភា ឆ្នាំ២០១០ ។

លោក *ឃុនសុវណ្ណណែត* បានសរសេរថា"*និយាយដោយខ្លីដោយសារថ្នាក់ដឹកនាំ និងអ្នកធ្វើយុទ្ធនាការរបស់អង្គការអ្នកពិតជាមានជម្ងឺឆ្កួតជ្រូកនិងបញ្ហាផ្លូវចិត្តផ្សេងៗទៀតនោះ វាជាការសមហេតុផលណាស់សំរាប់អ្នកតំណាង ឬមន្ត្រីកម្ពុជា ណាម្នាក់ក្នុងការមិនចូលរួមក្នុងកិច្ចពិភាក្សាដេញដោលនេះ*" ។

លោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* នៃប្រទេសកម្ពុជា ក៏ធ្លាប់បានរិះគន់ Global Witness ដែរ កាលពីឆ្នាំមុន ដោយបានហៅរបាយការណ៍ និងអ្នកជឿ ទៅលើរបាយការណ៍ របស់អង្គការ Global Witness នេះថា ជាអ្នកឆ្កួតលេលា ។ប៉ុន្តែលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ហាក់ដូចជាទទួលស្គាល់ របាយការណ៍នេះ ដោយមិនដឹងខ្លួន គឺខណៈដែលលោក បានដកលោក*ទី សុគន្ធ* ពីអគ្គ នាយករដ្ឋបាល ព្រៃឈើ កាលពីដើមខែមេសា ២០១០ ដោយសារតែគាត់ ពាក់ព័ន្ធទៅនឹងការបំផ្លាញព្រៃឈើដ៏រង្គាលនៅកម្ពុជា ។

លោក*ទីសុគន្ធ*ក៏មានឈ្មោះដ៏លេចធ្លោផងដែរនៅក្នុងរបាយការណ៍ស្តីពីការបំផ្លាញព្រៃឈើនៅកម្ពុជា ។

ដូច្នេះហើយ បានជា លោក*គង់ គាំ* មានប្រសាសន៍ថា "*ខ្ញុំមិនដឹងថាហោណាំបូរ៉ាឆ្កួតជ្រូក ឬអង្គការ Global Witness ឆ្កួតជ្រូកនោះទេ*" ៕

---

តមកពីទំព័រទី១ ន

ទាហានឈ្លានពាន ឈរជើងជាមួយទាហានខ្មែរ នៅលើទឹកដីខ្មែរនេះបានធ្វើអោយមន្ត្រីគណបក្សសម រង្ស៊ី រិះគន់ថា រដ្ឋាភិបាល ហាក់ដូចជា មិនច្បាស់ថាព្រំដែនកម្ពុជាជាមួយសៀមនៅត្រឹមណានោះទេ ។

អតីតមន្ត្រីជាន់ខ្ពស់ម្នាក់ នៃគណបក្សប្រជាជន សព្វថ្ងៃជាប្រធានស្តីទី គណបក្សប្រជាជន លោក*គង់ គាំ* បានប្រាប់ *ខ្មែរម្ចាស់ស្រុក* ថា ការអនុញ្ញាតឱ្យទាហានសៀម ឈរជើងនៅលើទឹកដីកម្ពុជា ជិត២ឆ្នាំនេះ ហាក់ដូចជារាជរដ្ឋាភិបាល គ្មានជំហរច្បាស់លាស់ ក្នុងការការពារនូវបូរណភាពទឹកដីទេ ។

លោក*គង់ គាំ* បានមានប្រសាសន៍ថា ដោយផ្តោតសំខាន់ទៅលើប្រាសាទព្រះវិហារ និងតំបន់នៅជុំវិញនោះដែលកម្ពុជាក្រោមព្រះរាជកិច្ចដឹកនាំ របស់សម្តេចឪ ព្រះ*នរោត្តម សីហនុ* មានសាលក្រម ទីក្រុងឡាអេ កាលពីថ្ងៃទី១៥ មិថុនា១៩៦២ ច្បាស់លាស់ហើយដែលបញ្ជាក់ថា ប្រាសាទព្រះវិហារ ជារបស់កម្ពុជា ។

លោក*គង់ គាំ* បានមានប្រសាសន៍ថា"*រដ្ឋាភិបាលធ្លាប់បាននិយាយតទល់ ជាមួយភាគីថៃយ៉ាងច្បាស់លាស់ អំពីវត្ត កែវសិក្ខាគីរីស្វារៈនេះ ថាជាអធិបតេយ្យភាពជាបូរណភាព ទឹកដីរបស់កម្ពុជាតែឯងអត់មានទាក់ទិនអ្វីជាមួយនឹងថៃទេ*" ។

ប្រធានស្តីទី គណបក្សសមរង្ស៊ីរូបនេះបានថ្កោលទោសអ្នកដែលចរចា ជាមួយថៃ តាំងតែពីដើមទី បើទោះបីជាគេដឹងថាថៃបានទន្ទ្រាន ចូលកាន់កាប់ដីជុំវិញប្រាសាទព្រះវិហារ និងវត្តកែវសិក្ខាគីរីស្វារៈហើយ, ជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ទន់ជ្រាយ ខុសឆ្គង និងខ្សោយ ។ លោកបានបន្តថា ការចរចានៅ

តទៅទំព័រទី៣ ន

---

តមកពីទំព័រទី១ ក

**ផ្សាយនូវបញ្ហានៃការបំផ្លិចបំផ្លាញធនធានធម្មជាតិនានាដោយការគ្រប់គ្រងរបស់រដ្ឋាភិបាលបក្សដដែលនេះ បានទាក់ទាញប្រតិកម្មខឹងខ្លាំងក្លារបស់អ្នកកាន់អំណាចនៅកម្ពុជា។ ហើយរឿងថ្មីបំផុតនោះគឺឯកអគ្គរដ្ឋទូតកម្ពុជាលោក ហោ ណាំបូរ៉ា កូនប្រុសរបស់រដ្ឋមន្ត្រីការបរទេស ហោ ណាំហុង នៃរដ្ឋាភិបាលបក្សប្រជាជនលោកហ៊ុនសែនក្នុងនាមជាតំណាងកម្ពុជាប្រចាំចក្រភពអង់គ្លេស គាត់បានបញ្ចេញប្រតិកម្មបបួល Global Witness ជជែកគ្នាជាសាធារណៈអំពីបញ្ហានោះ។**

**ប៉ុន្តែមិនបានប៉ុន្មានផង រដ្ឋាភិបាលបក្សប្រជាជននៃនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យដកខ្លួនថយពីគម្រោងនៃការជជែកគ្នាជាសាធារណៈ ដែល Global Witness បានព្រមរួចទៅហើយដើម្បីនឹងវែកញែកឱ្យឃើញ សខ្មៅ ថា អ្វីដែល Global Witness បានចុះផ្សាយនោះមានមូលដ្ឋានច្បាស់លាស់ពិតប្រាកដ និងមិនមានគោលដៅដើម្បីបង្ខូចសំអុយឈ្មោះគណបក្សប្រជាជនកាន់អំណាចក្នុងរដ្ឋាភិបាលនៅកម្ពុជានោះទេ។ នេះច្បាស់ណាស់ថា វាទៅជាជួយធ្វើឱ្យគេយល់ដោយនូវមូលដ្ឋានសមទំនងបំផុតថា មកពីរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានចំណុចដែលត្រូវបិទបាំងហើយខ្លាចគេដឹងជាសាធារណៈប្រសិនបើមានការជជែកគ្នាជាមួយ Global Witness នៅវេទិកានានានោះ ម្ល៉ោះហើយមានតែផ្លូវចាស់ គឺការប្រកាសដកខ្លួនថយពីការជជែកគ្នានោះ។**

**នេះមិនមានអ្វីគួរឱ្យងឿងឆ្ងល់នោះទេ ពីព្រោះក្នុងអតីតកាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃកម្ពុជាផ្ទាល់ក៏ធ្លាប់បានប្រកាសប្តឹងកាសែតបារាំង L´Expressដែលបានចុះផ្សាយរឿងរ៉ាវស្តីពី ស្នេហាលួចលាក់រវាងនាយករដ្ឋមន្ត្រីកម្ពុជា និងតារាសិល្បៈ ពិសិដ្ឋ ពិលិកា ដែលស្នេហានោះបាននាំទៅដល់សោកនាដកម្មនៃការស្លាប់យ៉ាងអណោចអធ័មនៃនាង ពិសិដ្ឋ ពិលិកា នោះ។**

**គឺជារឿងរ៉ាវដែលបានកើតមានឡើងកាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៩ ដោយឃាតកស៊ីឈ្នួលបានបាញ់តារាភាពយន្តនោះកណ្តាលផ្លូវអ៊ូរអរទាំងព្រឹកក្នុងទីក្រុងភ្នំពេញ ហើយក៏ធ្វើឱ្យនាងស្លាប់ដោយសារមុខរបួសនៅឯមន្ទីរពេទ្យកាល់ម៉ែត។ រឿងរ៉ាវនោះក្រោយមកក៏មានការបញ្ចេញឯកសារដោយប្អូនស្រីរបស់នាង ពិសិដ្ឋ ពិលិកា នៅគ្រាដែលបានចាកចេញពីកម្ពុជា ហើយបាននិយាយទស្សនាវដ្តី L´Epress ជាមួយការបង្ហាញវត្ថុតាងនានាអំពីទំនាក់ទំនងស្នេហារវាងអ្នកកាន់អំណាចនៅកម្ពុជា និងបងស្រីរបស់នាង។ គឺពេលនោះហើយដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសប្តឹងក្នុងបំណងលុបលាងកេរ្តិ៍ឈ្មោះរបស់លោកនៅឯតុលាការបារាំង ក៏ស្រាប់តែសម្រេចចិត្តដកខ្លួនថយមិនហ៊ានប្តឹងកាសែត L´Express របស់បារាំងនោះវិញ ទំនងជាដោយការយល់ថា បើនឹងប្តឹងតតាំងគ្នា វានឹងរឹតធ្លាយជាសាធារណៈ ហើយដែលគេពិបាកនឹងប៉ាន់ស្មានថានឹងមានរឿងអ្វីផ្សេងទៀតត្រូវទម្លាយឱ្យពិភពលោកដឹងនោះ។**

**ដូចគ្នានេះដែរ ការដែលកូនប្រុសរបស់ប្រមុខការទូតកម្ពុជាបានសម្រេចដកខ្លួនចេញពីគម្រោងបបួល Global Witness ជជែកគ្នាជាសាធារណៈស្តីពីការបូមខ្សាច់សមុទ្រខ្មែរដោយក្រុមហ៊ុនរបស់ឧកញ៉ា ម៉ុង ឫទ្ធី និងឧកញ៉ា លី យ៉ុងផាត់ មេឈ្មួញធំដែលជាសមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាច ជាបញ្ហាដែល Global Witness បានចុះផ្សាយថា មួយឆ្នាំៗរកបានប្រាក់ចំណូលរាប់សិបលានដុល្លារមិនដាក់ចូលថវិកាជាតិ ហើយទាំងធ្វើឱ្យប៉ះពាល់ដល់បរិស្ថានសមុទ្រ និងជីវភាពរបស់ពលរដ្ឋខ្មែរនៅតំបន់នោះផងដែរ។**

**តើមកពីមានរឿងអ្វីដែលរដ្ឋាភិបាលបក្សប្រជាជនមានការបារម្ភភ័យខ្លាចកាន់តែរីករាលដាលបង្ហាញសាធារណៈមតិជាតិ និងអន្តរជាតិឱ្យដឹងឮជុំវិញរឿងដែលនាយករដ្ឋមន្ត្រីបានបញ្ជាកាលក្នុងឆ្នាំ២០០៩ឱ្យបិទអាជីវកម្មបូមខ្សាច់ទាំងអស់ ប៉ុន្តែបែរជាស៊ីគ្រលំប្រគល់អាជ្ញាប័ណ្ណបន្តអាជីវកម្មបូមខ្សាច់ទៅឱ្យក្រុមហ៊ុនទាំងពីរ លី យ៉ុងផាត់ និងម៉ុង ឫទ្ធី ទៅវិញនោះ។ គ្មាននរណាដឹងថា មានបញ្ហាអ្វីទៀតដែល Global Witness មានបំណងនឹងលើកយកទៅបង្ហាញលោក ហោ ណាំបូរ៉ា ក្នុងនាមជាឯកអគ្គរដ្ឋទូតតំណាងរដ្ឋាភិបាលបក្សប្រជាជននៅប្រទេសអង់គ្លេសនោះទេ អំពីបញ្ហាបូមខ្សាច់នោះ ទើបបានជាមានបញ្ជាពីទីក្រុងភ្នំពេញឱ្យទូតខ្មែររូបនោះដកខ្លួនចេញពីការពិភាក្សាគ្នាជាសាធារណៈ។**

**និយាយដោយខ្លី ប្រាកដជាមកពីរដ្ឋាភិបាលបក្សប្រជាជននៃលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដឹងខ្លួនយ៉ាងច្បាស់ថាការជជែកគ្នាជាសាធារណៈនោះមិនផ្តល់ផលចំណេញអ្វីឱ្យអ្នកកាន់អំណាចនៅកម្ពុជា ក្រៅតែពីការកាន់តែធ្វើឱ្យបាក់មុខនិងបែករឿងវែងឆ្ងាយតទៅទៀតអំពីការគ្រប់គ្រងប្រទេសបណ្តាលឱ្យមានការបំផ្លិចបំផ្លាញធនធានធម្មជាតិនិងបរិស្ថានរបស់ប្រទេសកម្ពុជា នៅក្រោមការត្រួតត្រានិងការទទួលខុសត្រូវរបស់គណបក្សប្រជាជននៃលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុណ្ណោះនោះ។**

**គណបក្សប្រជាជនមានអត្តសញ្ញាណសម្គាល់អំពីសកម្មភាពនៃការដឹកនាំគ្រប់គ្រងនយោបាយរបស់ខ្លួននៅកម្ពុជាថានឹងមិនធ្វើអ្វីៗទាំងឡាយដែលនាំឱ្យខាតបង់ ជាពិសេសជាប្រយោជន៍នៃកេរ្តិ៍ឈ្មោះរបស់គណបក្សប្រជាជននោះទេ ក៏ប៉ុន្តែនឹងធ្វើអ្វីៗឱ្យតែបានផលចំណេញ បើទោះបីជាផលកម្រៃនៃការចំណេញនយោបាយនោះជាការខាតបង់មួយផ្នែកណារបស់ប្រទេសកម្ពុជា ឬប្រជារាស្ត្រខ្មែរនោះ។**

**ពួកអ្នកសង្កេតការណ៍និយាយថា ប្រសិនបើមានការជជែកគ្នាជាសាធារណៈរវាងលោក ហោ ណាំបូរ៉ា តទល់នឹងមន្ត្រី Global Witness មែននោះ ច្បាស់ណាស់ថា Global Witness នឹងបញ្ចេញឯកសារនានាជាការស្រាវជ្រាវសិក្សារបស់ខ្លួនជាមួយតឹកតាងសង្កត់បញ្ជាក់បន្ថែមអំពីកំហុសឆ្គងនៃការគ្រប់គ្រងប្រទេសដោយរដ្ឋាភិបាលបក្សប្រជាជន ដែលនាំទៅដល់ស្ថានភាពនៃការប៉ះពាល់ និងការបំផ្លិចបំផ្លាញបរិស្ថានធនធានធម្មជាតិរបស់ប្រទេសកម្ពុជានោះ៕**

